ក្រសួងយុត្តិធម៌

លេខ ៣២៥ រប-៩៣

# សាធារណរដ្ឋប្រជាមានិតកម្ពុជា

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ភ្នំពេញ ថ្ងៃទី ០៩ ខែកក្ក៥១ ៣១៩៥៨

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

- លោក ប្រធានតុលាការ ខេត្ត-ក្រុង

*<u>សូមជ្រាប</u>*

**<u>កម្មវត្ថុៈ</u>** -ការរៀបចំសំណុំរឿងបញ្ជូនទៅសាលាឧទ្ធរណ៍

**<u>យោងៈ</u>** -ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី០៨ ខែ០២ ឆ្នាំ១៩៩៣ ។

តាមកម្មវត្ថុ និងយោងខាងលើ ក្រសួងយុត្តិធម៌សូមជម្រាប លោកប្រធានតុលាការ ខេត្ត-ក្រុង ទាំងអស់ថាគ្រប់រឿងក្តីទាំងអស់ដែលតុលាការជំនុំជម្រះរួចហើយតែត្រូវភាគីណាមួយមិនសុខចិត្ត ហើយប្តឹងឧទ្ធរណ៍តាមសំណាចច្បាប់បើកផ្លូវឲ្យប្តឹងនោះតុលាការខេត្ត-ក្រុងទាំងអស់ត្រូវរៀបចំសំណុំរឿងទាំងអស់នោះទៅតាមនីតិវិធី នៃបែបបទប្តឹងឧទ្ធរណ៍ ត្រៀមបញ្ជូនទៅសាលាឧទ្ធរណ៍ដើម្បីធានានូវប្រយោជន៍ដល់គូក្តីដែលទាក់ទងក្នុងរឿងក្តី និងធានាភាពត្រឹមត្រូវតាមផ្លូវច្បាប់នៅពេលណាសាលាឧទ្ធរណ៍បើកដំណើរការជាផ្លូវការ ។

**រដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ចែម ស្នួន**